# កិច្ចព្រមព្រៀង

ថ្ងៃទី ២០ ខែមេសា ឆ្នាំ ២០២០ នៅក្រុមហ៊ុន ឌី & ប៊្លូ (ខេមបូឌា) ឯ.ក បានបើកកិច្ចប្រជុំមួយក្រោមអធិបតីភាពលោក ZHENG WENHE ជាតំណាងក្រុមហ៊ុន ស្តីពីការព្យួរកិច្ចសន្យាការងារមួយរយៈដោយមូលហេតុដោយសារវត្ថុធាតុដើមដែលត្រូវផលិតត្រូវបានផ្អាកមិនអាចនាំចូលបាន និងផលិតផលដែលផលិតរួចហើយមិនអាចនាំចេញបាន ធ្វើឲ្យប៉ះពាល់ដល់សង្វាក់ផលិតកម្មមិនអាចដំណើរការបានពេញលេញក្នុងរយៈ ០២ ខែ។

សមាសភាពចូលរួម៖

1- ភាគីតំណាងរោងចក្រ

- លោក ZHENG WENHE តំណាងនាយករោងចក្រ
- លោក ងួន ពិសិដ្ឋ ជាប្រធានរដ្ឋបាល និងជាអ្នកកត់ត្រា

2- ភាគីតំណាងកម្មករនិយោជិត

- លោកស្រី ស្វាយ រ័ត្នម៉ាលីន
- លោក អ៊ាង សាមីឌី

ក្រោយពិភាក្សាគ្នាយ៉ាងល្អិតល្អន់រួចមក ភាគីទាំងពីរបានឈានដល់កិច្ចព្រមព្រៀងដូចខាងក្រោម ៖

1- ក្រុមហ៊ុនសម្រេចព្យួរកិច្ចសន្យាការងារ កម្មករនិយោជិត ចំនួន ៣៥១ នាក់ ក្នុងចំណោមកម្មករសរុបចំនួន ៣៥១ នាក់ (ក្នុងនោះមានកម្មករនិយោជិតចំនួន ២៧ នាក់ មានពត៌មានមិនគ្រប់គ្រាន់) ក្នុងរយៈពេល ០២ ខែ ដោយគិតចាប់ពីថ្ងៃទី ០១ ខែឧសភា ឆ្នាំ២០២០ រហូតដល់ ថ្ងៃទី ៣០ ខែមិថុនា ឆ្នាំ២០២០។

2- ក្នុងអំឡុងពេលនៃការព្យួរកិច្ចសន្យាការងារនេះខាងតំណាងកម្មករទាំងអស់បានឯកភាពគ្នាព្រមទទួលយកប្រាក់ឧបត្ថម្ភដែលក្រុមហ៊ុនផ្តល់ជូន៣០ដុល្លាអាមេរិកនិងប្រាក់ឧបត្ថម្ភដែលរដ្ឋាភិបាលផ្តល់ជូន ៤០ដុល្លាអាមេរិក ក្នុងមួយខែ ដោយយោងទៅតាមសេចក្តីណែនាំស្តីពីការព្យួរកិច្ចសន្យាការងារលេខៈ ០៤៥/២០ ក.ប/ស.ណ.ន.ខ.ល ចុះថ្ងៃទី ១៧ ខែមេសា ឆ្នាំ២០២០ របស់ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ។

3- ក្រុមហ៊ុនបើកប្រាក់ឧបត្ថម្ភចំនួន ៣០ដុល្លាអាមេរិក មួយខែម្តង នៅរៀងរាល់ថ្ងៃទី ៣០ នៃខែឧសភា និងខែមិថុនា ឆ្នាំ២០២០។

4- ចប់ការព្យួរការងារកម្មករនិយោជិត ត្រូវមកចូលធ្វើការនៅកន្លែងដើមវិញ តាមតួនាទីភារកិច្ចរបស់ខ្លួន។

ការប្រជុំនេះចប់សព្វគ្រប់នៅវេលាម៉ោង១៥:៥០នាទី នាថ្ងៃទី ២០ ខែមេសា ឆ្នាំ២០២០ ដដែលក្រោមបរិយាកាសរីករាយ។

ព្រះរាជាណាចក្រកម្ពុជា ក្រុមហ៊ុន ឌី & ប៊្លូ (ខេមបូឌា) ឯ.ក D & BLUE (CAMBODIA) CO.,LTD. KINGDOM OF CAMBODIA

ថ្ងៃច័ន្ទ ១៣រោង ខែចេត្រ ឆ្នាំជូត ឯកស័ក ព.ស ២៥៦៤

រាជធានីភ្នំពេញ, ថ្ងៃទី ២០ ខែមេសា ឆ្នាំ២០២០

| | |
|---|---|
| បានឃើញនឹងឯកភាព | បានឃើញនឹងឯកភាព |
| តំណាងនាយកក្រុមហ៊ុន | តំណាងកម្មករ |
| ZHENG WENHE | ស្វាយ រ័ត្នម៉ាលីន    អ៊ាង សាមីឌី |

អ្នកកត់ត្រា

ងួន ពិសិដ្ឋ